# ការគាំទ្រកុមារពិការនៅក្នុងការថែទាំក្នុងគ្រួសារ

Better Care Network

## សេចក្ដីសង្ខេបអំពីវីដេអូ

កុមារគ្រប់រូបមានសិទ្ធិស្មើគ្នាក្នុងការរីករាយនឹងជីវិតក្នុងគ្រួសារ និងសហគមន៍។ ប៉ុន្តែ នៅក្នុងបរិបទជាច្រើន កុមារពិការបន្តត្រូវបានបំបែក និង បាត់បង់ការថែទាំក្នុងគ្រួសារ ដើម្បីទទួលបានសេវាដែលមានផ្តល់ជូន តែនៅក្នុងមណ្ឌលថែទាំកុមារ។ ដើម្បីធ្វើឱ្យនិន្នាការនេះមានភាពបញ្ច្រាសមកវិញ និងលើកកម្ពស់សិទ្ធិ និងឧត្តមប្រយោជន៍របស់កុមារពិការ យើងត្រូវអភិក្រមថ្មីដើម្បីធ្វើឱ្យការថែទាំតាម សហគមន៍ និងតាមគ្រួសារមានលក្ខណៈប្រកបដោយបរិយាប័ន្នសម្រាប់កុមារពិការ។ ចំណុចនេះទាមទារឱ្យមានការអភិវឌ្ឍសេវាដែលកុមារនៅក្នុងសហគមន៍អាចមានលទ្ធភាពទទួលបាន និង ផ្តល់កិច្ចគាំទ្រឯកទេសសម្រាប់អ្នកថែទាំកុមារ។ នៅក្នុងវីដេអូដែលត្រូវបានបែងចែកជាពីរវគ្គនេះ អ្នកនឹងស្តាប់លឺនូវមតិយោបល់របស់ ស៊ិន ស្រីនី និង លីសា យ៉ាន់ឃី ដែលជាអ្នក អនុវត្តការងារផ្ទាល់នៅក្នុងគម្រោង ABLE របស់អង្គការកុមារក្នុងគ្រួសារ ខណៈពេលដែលពួកគេចែករំលែកបទពិសោធន៍របស់ពួកគេ អំពីការធ្វើឱ្យការថែទាំកុមារតាមគ្រួសារក្នុងប្រទេសកម្ពុជា ប្រកបដោយបរិយាប័ន្នសម្រាប់កុមារពិការ។

នៅក្នុងវីដេអូវគ្គទី១ ស្រីនី និង លីសា ពិភាក្សាអំពីចំណុចរៀនសូត្រសំខាន់ៗរបស់ពួកគេ ទាក់ទងនឹងការ គាំទ្រអ្នកថែទាំកុមារ រួមទាំងសារៈសំខាន់នៃការគ្រប់គ្រងវិបត្តិតានតឹង (ស្ត្រេស) និង ការរំពឹងទុក ការអភិវឌ្ឍ ទំនាក់ទំនងគួរឱ្យជឿទុកចិត្ត និង ការអនុវត្តអភិក្រមគ្រួសារទាំងមូលដើម្បីផ្តល់ការគាំទ្រ។

នៅក្នុងវីដេអូវគ្គទី២ ពួកគេនិយាយអំពីបទពិសោធន៍ និងការរៀនសូត្ររបស់ពួកគេជុំវិញការជ្រើសរើសគ្រួសារធម៌ដើម្បីថែទាំកុមារពិការ រួមទាំងប្រភេទគ្រួសារដែលត្រូវកំណត់គោលដៅ និង របៀបប្រើប្រាស់ ជនគំរូដើម្បីដោះស្រាយបញ្ហាការមាក់ងាយនៅក្នុងសហគមន៍។

## ចំណុចពិភាក្សា៖

### ការរើសអើងមុខងារ

នៅក្នុងវីដេអូនេះ លីសា ពិភាក្សាអំពី “ការរើសអើងមុខងារ” ដោយរៀបរាប់អំពីចំណុចនេះថាជាការរើសអើង ដោយអចេតនា ដែលកើតឡើងនៅពេលដែលអង្គការមិនបានចាត់វិធានការផ្ទៃក្នុងដើម្បីធ្វើឱ្យកម្មវិធីរបស់ពួកគេមានលក្ខណៈប្រកបដោយបរិយាប័ន្ន និង បង្កលក្ខណៈឱ្យជនពិការអាចទទួលបានសេវា។

## នៅក្នុងបរិបទរបស់អ្នក៖

- តើអង្គការរបស់អ្នកបានអនុវត្តការងារជម្រុញឱ្យមានបរិយាប័ន្នយ៉ាងដូចម្តេច និង តើមានទិដ្ឋភាពណាខ្លះនៃសេវា និងកម្មវិធីរបស់អ្នក ដែលមិនទាន់បង្កលក្ខណៈឱ្យកុមារពិការអាចទទួលបាន ដែរឬទេ?
- តើមានអ្វីបន្ថែមទៀតដែលអាចធ្វើបាន ដើម្បីឱ្យកម្មវិធីរបស់អ្នកកាន់តែមានបរិយាប័ន្ន និងបង្ការមិនឱ្យមានការរើសអើងមុខងារ?
- តើអ្នកអាចត្រូវការសេវា ឬ កិច្ចគាំទ្រឯកទេសអ្វីខ្លះ ដើម្បីអភិវឌ្ឍ ឬ បំពេញបន្ថែមទៅលើប្រតិបត្តិការ បច្ចុប្បន្នរបស់អ្នក?
- តើមានឧបសគ្គអ្វីខ្លះ (ធនធាន សមត្ថភាព ជំនាញឯកទេស។ល។) ដែលអ្នកអាចត្រូវជំនះ ដើម្បីឱ្យ ក្លាយជាអង្គការមួយប្រកបដោយបរិយាប័ន្ន? តើអ្វីខ្លះជាជំហានបន្ទាប់ដែលអ្នកអាចអនុវត្តបានជាក់ស្តែង ដើម្បីជម្រុញរបៀបវារៈនេះឱ្យទៅមុខ?

### ចំណុចពិភាក្សា៖

## ការដោះស្រាយបញ្ហាការមាក់ងាយ និងការរើសអើង

នៅក្នុងវីដេអូនេះ ស្រីនី ពិភាក្សាអំពីបុព្វហេតុវប្បធម៌មួយចំនួនដែលនាំឱ្យមានការរើសអើង និងការមាក់ងាយ ជុំវិញពិការភាព និង និយាយអំពីរបៀបដែលអ្វីទាំងអស់នេះធ្វើឱ្យមានភាពស្ទាក់ស្ទើរនៅក្នុងគ្រួសារ ក្នុងការថែទាំកុមារពិការ។ ស្រីនី បានបន្តលាតត្រដាងអំពីរបៀបដែលជនគំរូ បានដើរតួនាទីសំខាន់នៅក្នុងការដែល CIF អាចកាត់បន្ថយការមាក់ងាយ និង បង្កើនចំនួនគ្រួសារដែលមានឆន្ទៈក្នុងការផ្តល់ការថែទាំក្នុងលក្ខណៈជាគ្រួសារធម៌ដល់កុមារដែលមានសេចក្តីត្រូវការពិសេស។

### នៅក្នុងបរិបទរបស់អ្នក៖

- តើមានជំនឿ និងការយល់ខុសអ្វីខ្លះ ជុំវិញបញ្ហាពិការភាពដែលនាំឱ្យមានការមាក់ងាយ និងការរើសអើង?
- តើបច្ចុប្បន្ន ការមាក់ងាយ និងការរើសអើងបង្កឱ្យមានផលប៉ះពាល់ដូចម្តេចខ្លះទៅលើលទ្ធភាពរបស់អ្នកក្នុងការធ្វើឱ្យសេវារបស់អ្នកប្រកបដោយបរិយាប័ន្ន?
- តើអ្នកអាចប្រើប្រាស់យុទ្ធសាស្ត្រអ្វីខ្លះ ដើម្បីកាត់បន្ថយការមាក់ងាយ និងតើយុទ្ធសាស្ត្រទាំងនេះអាចត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីរបស់អ្នកដោយរបៀបណា?

### ករណីសិក្សា

ដេត គឺជាកុមារាម្នាក់អាយុ៥ឆ្នាំ នៅពេលដែលគាត់ចូលក្នុងកម្មវិធីថែទាំដោយញាតិរបស់ CIF លើកដំបូង។ ម្តាយរបស់ដេត គឺជាស្ត្រីមេម៉ាយ ហើយគាត់បានទុកដេតឱ្យម្តាយមីងជាអ្នកថែទាំ។ ដេតមានជំងឺពិការចលករខួរក្បាល (Cerebral Palsy) ដោយសារតែដេតមានជំងឺ និងកន្ត្រាក់ខ្លាំងកាលដែលដេតនៅជាទារក។ ដេតមានការអភិវឌ្ឍយឺតយ៉ាវខាងផ្នែកខួរក្បាលការប្រាស្រ័យទាក់ទង និងរាងកាយ ព្រមទាំងខ្វះអាហារូបត្ថម្ភ។ បើទោះបីមានកិច្ចខិតខំប្រឹងប្រែងខ្លាំងក្លាក្នុងការផ្តល់ប្រឹក្សា និង ផ្តល់កិច្ចគាំទ្រគ្រប់ជ្រុងជ្រោយ ជូនដល់សាខាញាតិរបស់ដេតយ៉ាងណាក៏ដោយ ក៏ម្តាយមីងរបស់ដេតនៅតែមិនអាចផ្តល់ការថែទាំឱ្យបានគ្រប់គ្រាន់ និង បានស្នើសុំឱ្យយកដេតទៅទុកដាក់ជាមួយគ្រួសារធម៌មួយ។ បុគ្គលិករបស់ CIF បានអនុវត្តដំណើរការធ្វើការងារជាមួយអាជ្ញាធរ និងគ្រួសារដើម្បីទុកដាក់ដេតនៅក្នុងគ្រួសារធម៌មួយ។

បុគ្គលិកសង្គមកិច្ចរបស់ CIF បានផ្តល់ប្រឹក្សាជាច្រើនមុនពេកធ្វើការទុកដាក់ដេតជាមួយគ្រួសារធម៌ ដើម្បីធានាថាពួកគេបានដឹងទាំងស្រុង អំពីសេចក្តីត្រូវការកិច្ចគាំទ្ររបស់ដេត តម្រូវការផ្នែកអាហារូបត្ថម្ភ និងទិដ្ឋភាពផ្នែកអភិវឌ្ឍ។ គេបានធ្វើការងារជាមួយគ្រួសារនេះ ដើម្បីកំណត់រកអំពីរបៀបដែលការថែទាំដេតអាចបង្កឱ្យមានផលប៉ះពាល់ទៅលើការ ចូលរួមរបស់ពួកគេនៅក្នុងជីវិតសហគមន៍ និង តើមានកិច្ចគាំទ្រអ្វីខ្លះដែលគេអាចត្រូវការ ដើម្បីធានាថាការថែទាំ ដេតនៅតែបន្ត។ នៅពេលដែលគេធ្វើការទុកដាក់ដេត ពេទ្យព្យាបាលដោយចលនា របស់ CIF បានចាប់ផ្តើមផ្តល់ការព្យាបាលដោយចលនានៅឯផ្ទះជាមួយដេត ដោយបង្កលក្ខណៈឱ្យមានការចូលរួមពីអ្នកថែទាំរបស់ដេត និងបច្ចេកទេសធ្វើជាគំរូ ដែលពួកគេអាចប្រើប្រាស់បាន ដើម្បីធ្វើការងារជាមួយដេតជារៀងរាល់ថ្ងៃ។ ពួកគេបានលើកទឹកចិត្តគ្រួសារឱ្យបង្កលក្ខណៈឱ្យដេតអាចចូលរួមនៅក្នុងជីវិតគ្រួសារប្រចាំថ្ងៃ និង រៀបចំនូវគំរូមួយដើម្បីឱ្យសកម្មភាពនេះអាចប្រព្រឹត្តទៅបាន។ ដេតបានឆ្លើយតបយ៉ាងឆាប់រហ័សទៅនឹងភាពកក់ក្តៅ និងក្តីស្រឡាញ់ដែលគាត់ទទួលបានពីគ្រួសារធម៌ ហើយអាកប្បកិរិយាចេះលេងសើចនិងខ្និខ្នក់របស់គាត់ក៏ចាប់ផ្តើមកើតចេញមកដែរ។ កម្លាំង និងការគ្រប់គ្រងទៅលើការប្រើប្រាស់ជើងរបស់គាត់ក៏មានភាព រីកចម្រើនខ្លាំងផងដែរ ដោយ CIF បានគាំទ្រគាត់ឱ្យទទួលបានឧបករណ៍រណបជើង ដើម្បីការពារសន្លាក់របស់គាត់ និងធ្វើឱ្យឥរិយាបថរាងកាយរបស់គាត់មានភាពប្រសើរឡើង។ បុគ្គលិកបានអមដំណើរដេតនិង ឪពុកម្តាយធម៌របស់គាត់ទៅមន្ទីរពេទ្យដើម្បីអបឧបករណ៍រណបដែលធ្វើឡើងដោយអង្គការមួយទៀតដែលមានជំនាញឯកទេសខាងផ្នែកឧបករណ៍សិប្បនិម្មិត និងរណប។ ក្រុមការងារ ABLE បានធ្វើឧបករណ៍រណបជំនួយការធ្វើដំណើរមួយពីបំពង់ទុយោជូនគាត់ និង បង្ហាញគ្រួសារធម៌របស់គាត់អំពីរបៀបជួយដល់គាត់ ក្នុងការប្រើប្រាស់ឧបករណ៍នេះប្រកបដោយសុវត្ថិភាព។ ដេតស្រាប់តែអាចដើរបានយ៉ាងឆាប់រហ័សដោយខ្លួនឯង និងបានទទួលការទះដៃអបអរសាទរពីគ្រួសារ និងអ្នកជិតខាងរបស់គាត់។ លទ្ធភាពក្នុងការបំលាស់ទីនាពេលថ្មីៗនេះ បានបង្កលក្ខណៈឱ្យដេតអាចចូលរួមធ្វើសកម្មភាពជាច្រើននៅក្នុងសហគមន៍ជាមួយគ្រួសាររបស់គាត់។

ក្រុមការងារ ABLE ក៏កំពុងធ្វើការងារជាមួយដេត និងគ្រួសាររបស់ដេតអំពីយុទ្ធសាស្ត្រក្នុងការ កែលម្អសមត្ថភាពខាងផ្នែកភាសា និងបំណិនចលកររបស់ដេតផងដែរ។ សេវាព្យាបាលសមត្ថភាពខាងផ្នែកនិយាយស្ដីនៅមិនទាន់មានក្នុងប្រទេសកម្ពុជានៅឡើយ ដូច្នេះ អ្នកអនុវត្តការងាររបស់ ABLE បានទទួល ការបណ្តុះបណ្តាល និង កំពុងកសាងសមត្ថភាពរបស់ពួកគេដើម្បីបញ្ចូលសេវានេះទៅក្នុងកិច្ចគាំទ្រដែលពួកគេផ្តល់ជូន

គ្រួសារ។ បុគ្គលិករបស់ ABLE ចុះសួរសុខទុក្ខគ្រួសាររបស់ដេតជាទៀងទាត់ និង ចំណាយពេលវេលាជាមួយពួកគេ ត្រួតពិនិត្យកម្រិតនៃវិបត្តិតានតឹង (ស្ត្រេស) របស់ពួកគេ និងធានាថាពួកគេទទួលបានកិច្ចគាំទ្រល្អប្រសើរ ខណៈពេលដែលពួកគេបន្តថែទាំដេត។ សាលារៀនក្នុងមូលដ្ឋាន មិនទាន់បានបំពាក់ឧបករណ៍ដើម្បីផ្តល់ការអប់រំប្រកបដោយបរិយាប័ន្ន ឬការអប់រំបែបរួមបញ្ចូលគ្នា ដើម្បីផ្តល់ជូនឱ្យស្របតាមសេចក្តីត្រូវការរបស់កុមារ ដូចជាដេតឡើយ។ ដូច្នេះ អាស្រ័យដោយឥឡូវនេះដេតមានអាយុ៥ឆ្នាំ និង កំពុងជិតដល់អាយុចូលរៀន បុគ្គលិករបស់ ABLE នឹងធ្វើការងារជាមួយសាលារៀន និងគាំទ្រដេតឱ្យទទួលបានការអប់រំក្នុងបរិយាកាសមួយដែលសមស្របទៅនឹងសេចក្តីត្រូវការរបស់គាត់។